**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤៣៥/២៣ មស.សជណ

ថ្ងៃ អង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាពនានាចំណុះក្រសួង និងមន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា ក្រសួងមុខងារសាធារណៈនឹងធ្វើការជ្រើសរើសមន្ត្រីដែលមានលក្ខណៈសម្បត្តិសមស្រប ឱ្យទទួលមុខតំណែងជាអនុប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ ដើម្បីបំពេញបន្ថែមលើចំនួនអនុប្រធាននាយកដ្ឋានដែលមានស្រាប់។

បេក្ខជនត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖
- មានសញ្ញាបត្រផ្នែកនីតិសាស្ត្រ ឬផ្នែករដ្ឋបាលសាធារណៈ ឬផ្នែកជំនាញប្រហាក់ប្រហែល
- មានបទពិសោធន៍ការងារចាប់ពី ៣ឆ្នាំឡើងទៅ
- មានសមត្ថភាពអាចប្រើប្រាស់ភាសាបរទេសបាន
- ចេះធ្វើការជាក្រុម។

ការជ្រើសរើសនឹងដំណើរការដោយផ្អែកតាមគោលការណ៍គុណាធិបតេយ្យ ដោយបេក្ខជនត្រូវឆ្លងកាត់ការប្រឡងវិញ្ញាសាសរសេរ និងកិច្ចសម្ភាសន៍។

មន្ត្រីរាជការទាំងអស់ដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញមកដាក់ពាក្យស្នើសុំចូលរួមការប្រឡងនៅនាយកដ្ឋានគ្រប់គ្រងបុគ្គលិកនៃទីស្តីការក្រសួងមុខងារសាធារណៈ ចាប់ពីពេលជូនដំណឹងនេះតទៅរហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

ព័ត៌មានលម្អិតបន្ថែម៖ លេខទូរស័ព្ទ 012 811 977, 017 779 998 និង 012 558 126៕

ត.ប.**រដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**អគ្គនាយករងអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ**

**សយ រតនៈ**